CITY OF LONGBEACH PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ១៦ ខែមិថុនាឆ្នាំ ២០២០

ទំនាក់ទំនង៖ Susan Jones, Manager of Main Library Services, Long Beach Public Library, 562.570.6608, Susan.Jones@lbpl.org

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# បណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិចនឹងបើកដំណើរការកម្មវិធីក្នុងរដូវក្តៅរបស់យុវវ័យ

*កម្មវិធី 'Make.Create.Design' នឹងបង្រៀនក្មេងវ័យជំទង់ឱ្យចេះរចនានិងបង្កើតវីដេអូហ្គេមដោយខ្លួនឯង*

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - ចាប់ពីថ្ងៃទី ៣០ ខែមិថុនាសិស្សថ្នាក់ទី ៧ ដល់ ១២ អាចរៀនរចនានិងបង្កើតវីដេអូហ្គេមដោយខ្លួនឯងតាមរយៈកម្មវិធី "Make.Create.Design." ដែលជាកម្មវិធីយុវវ័យប្រចាំឆ្នាំក្នុងរដូវក្តៅរបស់បណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិច (LBPL)។ វគ្គសិក្សាតាមអ៊ិនធរណេតនេះដែលមានរយៈពេល ៦ សប្តាហ៍នឹងណែនាំអ្នកចូលរួមអំពីជំនាញអាជីពដ៏មានតម្លៃនៅក្នុងឧស្សាហកម្មវីដេអូហ្គេមដែលជាឧស្សាហកម្មមួយដែលរីកលូតលាស់លឿនបំផុតនៅភាគខាងត្បូងនៃរដ្ឋកាលីហ្វ័រញ៉ា។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "ក្មេងជំទង់នឹងមានកន្លែងនៅលើអ៊ិនធរណេតដើម្បីបង្ហាញពីការច្នៃប្រឌិតរបស់ពួកគាត់តាមរយៈកម្មវិធីបណ្ណាល័យសាធារណៈនៅរដូវក្តៅនេះ។ កម្មវិធីនៅឆ្នាំនេះដែលមានឈ្មោះថា Make.Create.Design បង្រៀនអ្វីៗគ្រប់យ៉ាងតាំងពីកម្មវិធីហ្គេមវីដេអូរហូតដល់សម្លេងនិងសិល្បៈហើយគឺផ្តល់ជូនដោយឥតគិតថ្លៃ។"

កម្មវិធី "Make.Create.Design" នឹងចាប់ផ្តើមពីថ្ងៃទី ៣០ ខែមិថុនាដល់ថ្ងៃទី ៦ ខែសីហាដោយមានសិក្ខាសាលាតាមអ៊ីនធឺណេតដែលនឹងមាននៅថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ចាប់ពីម៉ោង ២ រសៀលដល់ម៉ោង ៤ ល្ងាច។ ដឹកនាំដោយអ្នកណែនាំស្ទូឌីយ៉ូនៅកន្លែងផលិតនៅបណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិចនិស្សិតនឹងអាចបង្កើតហ្គេមផ្ទាល់ខ្លួនពីដំបូងតាមរយៈសិក្ខាសាលាស្តីពីការនិទានរឿង កម្មវិធីសិល្បៈនៃរូបភាព និងការរចនាសំលេង។ សិក្ខាសាលាត្រូវបានរៀបចំឡើងសម្រាប់សិស្សថ្នាក់ទី ៧ ដល់ទី ១២ ហើយអ្នកចូលរួមទាំងអស់ត្រូវមានប័ណ្ណបណ្ណាល័យ។

លោកស្រី Glenda Williams នាយកមន្ទីរសេវាកម្មបណ្ណាល័យបានមានប្រសាសន៍ថា "បណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិចប្តេជ្ញាបន្តផលិតធនធានច្នៃប្រឌិតនិងមានប្រយោជន៍ដល់អតិថិជនជាពិសេសតាមរយៈស្ទូឌីយោកន្លែងផលិតរបស់យើង។ Make.Create.Design គឺជាប្រពៃណីនៅរដូវក្តៅដ៏រីករាយនិងអប់រំសម្រាប់យុវវ័យរបស់យើងហើយផងដែរបុគ្គលិករបស់យើងបានខិតខំបង្កើតកម្មវិធីតាមអ៊ីនធឺណេតនេះដែលអាចចូលប្រើបាននិងគួរឱ្យរំភើប។"

ដើម្បីចុះឈ្មោះចូលរួមសិក្ខាសាលាឥតគិតថ្លៃទាំងនេះសូមចូលទៅកាន់ផ្ទាំងការរៀនសូត្រ (Learning Tab) នៅលើគេហទំព័ររបស់បណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិច។ បុគ្គលដែលមិនទាន់មានប័ណ្ណបណ្ណាល័យអាចដាក់ពាក្យសុំកាតឥតគិតថ្លៃនៅលើគេហទំព័ររបស់បណ្ណាល័យ។

សម្រាប់ព័ត៌មានបន្ថែមអំពីកម្មវិធីនេះសូមទាក់ទងបណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិចតាមរយៈលេខ 562.570.7500 ចន្លោះម៉ោង ១០ ព្រឹកទៅម៉ោង ៥ ល្ងាចពីថ្ងៃអង្គារដល់ថ្ងៃសៅរ៍។ កម្មវិធីរដូវក្តៅប្រចាំឆ្នាំនេះគឺគាំទ្រដោយមូលនិធិបណ្ណាល័យសាធារណៈឡុងប៊ិច។

**អំពីទីក្រុងឡុងប៊ិច**

ជាទីលំនៅដ្ឋាននៃប្រជាជនប្រមាណ ៤៨០,០០០ នាក់ទីក្រុងឡុងប៊ិចបានទទួលពានរង្វាន់និងជាទីក្រុងច្នៃប្រឌិតដែលផ្តល់ជូននូវភាពសំបូរបែបនៃពិភពលោកខណៈពេលដែលរក្សាលក្ខណៈបុគ្គលនិងដែលបង្កើតឡើងពីសង្កាត់ផ្សេងៗពីគ្នាដែលបានផ្តុំនៅតាមបណ្តោយឆ្នេរសមុទ្រប៉ាស៊ីហ្វិក។ ក្នុងនាមជាទីក្រុងដែលមានសេវាកម្មពេញលេញទីក្រុងឡុងប៊ិចជាលំនៅដ្ឋានរបស់នាវា Queen Mary, អាងចិញ្ចឹមត្រីនៃមហាសមុទ្រប៉ាស៊ីហ្វិក (Aquarium of the Pacific), សារមន្ទីរនិងរោងកុនជាច្រើន, សាលារៀនដែលត្រូវបានវាយតម្លៃខ្ពស់, អាកាសយានដ្ឋានឡុងប៊ិច, កំពង់ផែឡុងប៊ិច ក៏ដូចជាមន្ទីរផ្សេងៗដែលបា

នទទួលពានរង្វាន់ជាច្រើនដូចជាមន្ទីរសុខាភិបាល មន្ទីរឧទ្យានការកំសាន្តនិងសមុទ្រ មន្ទីរសេវាកម្មអភិវឌ្ឍន៍ និងមន្ទីរផ្សេងៗទៀត។ ទីក្រុងនេះក៏មានសាកលវិទ្យាល័យនិងមហាវិទ្យាល័យដែលត្រូវបានការគោរពខ្ពស់ ក៏ដូចជាកន្លែងចិញ្ចឹមសត្វជាប្រវត្តិសាស្ត្រចំនួន២ មន្ទីរពេទ្យ៥ ទីតាំង៥សម្រាប់លេងហ្គោល សួន១៧០ ឆ្នេរសមុទ្រជាច្រើនម៉ាយល៍ម៉ា ផ្លូវសម្រាប់ជិះកង់ និងកម្មវិធីជិះកង់ដែលមានការចែករំលែក។

សម្រាប់ព័ត៌មានបន្ថែមអំពីទីក្រុងឡុងប៊ិចសូមចូលទៅកាន់គេហទំព័រ http://longbeach.gov/។ សូមតាមដានទីក្រុងឡុងប៊ិចនៅលើបណ្តាញសង្គមសម្រាប់ព័ត៌មានថ្មីៗនៅលើ ហ្វេសប៊ុក ធ្វីតធ័រ Instagram និង យូធ្យូប។

## អំពីបណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិច

បណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិចត្រូវបានបង្កើតឡើងក្នុងឆ្នាំ 1896 ដែលបម្រើដល់ទីក្រុងចម្រុះដែលមានប្រជាជនជិតកន្លះលាននាក់។ ប្រព័ន្ធបណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិចរួមមានបណ្ណាល័យ Billie Jean King Main Library និងបណ្ណាល័យសង្កាត់ចំនួន 11 និងវត្តមាននៅលើអ៊ីនធឺណិតយ៉ាងរស់រវើក។ នៅរដូវក្តៅឆ្នាំ 2017 បណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិចបានទទួលពានរង្វាន់មេដាយថ្នាក់ជាតិសម្រាប់បណ្ណាល័យនិងសារមន្ទីរក្នុងការទទួលស្គាល់ការសហការសហគមន៍ដែលមានការជោគជ័យ ព្រមទាំងកម្មវិធីវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) ប្រកបដោយភាពច្នៃប្រឌិតក៏ដូចជាការផ្តល់កម្មវិធីផ្តោតលើអក្ខរកម្មដល់ប្រជាជននៅទីក្រុងឡុងប៊ិច។ ដោយផ្តោតលើការផ្តល់ព័ត៌មានដោយឥតគិតថ្លៃនិងស្មើភាពគ្នានិងការគាំទ្រការរៀនសូត្រពេញមួយជីវិតបណ្ណាល័យផ្តល់ជូននូវសៀវភៅ ប្រព័ន្ធផ្សព្វផ្សាយ មូលដ្ឋានទិន្នន័យ អ៊ិនធឺណែត មជ្ឈមណ្ឌលសិក្សាជាលក្ខណៈគ្រួសារ កន្លែងផលិតនិងព្រឹត្តិការណ៍ជាច្រើនទៀតរាប់ចាប់ពីការនិទានរឿងរហូតដល់កម្មវិធីវប្បធម៌។

សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ www.lbpl.org។ សូមមេត្តាចូលចិត្ត (Like) បណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិចនៅលើបណ្តាញសង្គម Facebook និងតាមដានយើងខ្ញុំតាមបណ្តាញសង្គម Twitter និង Instagram។

###